# ព្រះរាជក្រឹត្យ

នស/រកត/០៣១០/២៥៧

## ស្តីពី

## ការកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២
## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩
## ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងបរិយាជីវមណ្ឌលបឹងទន្លេសាប

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា៣ មាត្រា៥ មាត្រា៦ មាត្រា៩ មាត្រា១០ និងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអាជ្ញាធរទន្លេសាប ដូចតទៅ ៖

**មាត្រា៣ថ្មី.-**

**អ.ទ.ស.** មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| -ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| -ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| -ឥស្សរជនជាន់ខ្ពស់ | ០១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| -រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| -រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| -អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| -ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| -តំណាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| -អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| -អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| -អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |
| -អគ្គនាយកអាជ្ញាធរអប្សរា | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម | | សមាជិក |
| -អភិបាលនៃគណៈអភិបាលខេត្តកណ្តាល | | សមាជិក |

សមាសភាពជាក់ស្តែងរបស់ **អ.ខ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៥ថ្មី.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| -ប្រធាន អ.ទ.ស. | ប្រធាន |
| -អនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ អ.ទ.ស. | អនុប្រធាន |
| -អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| -អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក ។ |

**មាត្រា៦ថ្មី.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប ជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងអនុប្រធានអចិន្ត្រៃយ៍ ព្រមទាំងទីប្រឹក្សាមួយចំនួនជាជំនួយការ ។

**មាត្រា៩ថ្មី.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ជាបន្ទុករបស់ក្រសួងធនធានទឹក និងឧតុនិយម ។

**មាត្រា១០ថ្មី.-**

**អ.ទ.ស.** មានសិទ្ធិប្រើត្រាដោយឡែករបស់ខ្លួន ។

**មាត្រា១២ថ្មី.-**

ប្រភពធនធានថវិការបស់ **អ.ទ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

-ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំ របស់ក្រសួងធនធានទឹក និងឧតុនិយម

-អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា

-ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

**អ.ទ.ស.**មានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុងប្រទេស និងក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព ។

មាត្រាពីរ.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិនា ឆ្នាំ២០១០

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបង្គាប់**

៣,ល.១០០៣.២៦១

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**លេខ:៧៥៧ ច.ល**

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១០

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**



5/5